# អរិយធម៌គុស ( Kush civilization)

អរិយធម៌គុស ( Kush civilization ) ឬ ហៅម៉្យាងទៀតថា អរិយធម៌នៃអាណាចក្រគុស (Kush empire civilization) ដែលជា អរិយធម៌ចំណាស់មួយនៅក្នុងទ្វីបអាហ្វ្រិចបន្ទាប់ពីអរិយធម៌អេហ្ស៊ីប។ អរិយធម៌នេះកើតឡើងចេញពីតំបន់នូប៊ីន (Nubian) ដែលជាតំបន់បុរាណមួយដែលស្ថិតនៅខាងជើងនៃទ្វីបអាហ្វ្រិចដែលលាតសន្ធឹងពីទន្លេនីល រហូតដល់សមុទ្រក្រហម ហើយសព្វថ្ងៃស្ថិតនៅខាងជើងនៃប្រទេសស៊ូដង់ (Sudan) និងស្ថិតនៅខាងត្បូងនៃប្រទេសអេហ្ស៊ីប[១] (រូបលេខ១)។ ទីក្រុងសំខាន់ៗនៃអាណាចក្រនេះរួមមាន ទីក្រុង Napata និងទីក្រុង Meroë ដែលអ្នកស្រាវជ្រាវផ្សេងៗបានបង្ហាញថាអរិយធម៌នេះ មានឥទ្ធិពលខ្លាំងក្លានៅក្នុងតំបន់នៅរវាងស.វ.ទី ៣មុនគ.ស. ហើយក៏ជាតំបន់នៃពាណិជ្ជកម្មដោះដូររវាងតំបន់អាហ្វ្រិកឧបទ្វីបអារ៉ាប់ និងតំបន់សមុទ្រមីឌីទែរ៉ាណេ[២] ជាពិសេសការជួញដូរលើឧស្សាហកម្មដែក និងមាសជាដើម(រូបលេខ២-៣)។ ទីក្រុងទាំងនោះស្ថិតនៅតំបន់វាលខ្សាច់សាហារ៉ា។ អរិយធម៌នេះក៏មិនខុសអ្វី ពីអរិយធម៌អេហ្ស៊ីបនោះទេ ដោយសារជ្រើសរើសយកទីតាំងតំបន់ទន្លេនេះគឺស្របទៅតាមវិស័យកសិកម្ម នេសាទ និងការចិញ្ចឹមសត្វ ដែលពឹងផ្អែកទៅលើប្រភពទឹក។

សង្គមអរិយធម៌នៅក្នុងអាណាចក្រគុស ក៏មិនខុសអ្វីពីអាណាចក្រអេហ្ស៊ីបនោះទេ ពោលគឺ ពួកគេទទួលឥទ្ធិពលពីអរិយធម៌អេហ្ស៊ីបទាំងការប្រើប្រាស់ប្រព័ន្ធ នយោបាយ សាសនា ភាសា និងអក្សរ ដូចគ្នាទៅនឹងអរិយធម៌អេហ្ស៊ីបដែរ គឺដូចនឹងអាណាចក្រអេហ្ស៊ីបថ្មីមួយអញ្ចឹងដែរ។ មនុស្សក្នុងអរិយធម៌នេះគោរពប្រតិបត្តិអទិទេពដូចនឹងមនុស្សក្នុងអរិយធម៌អេហ្ស៊ីបដែរ។ សំណង់ប្រាសាទពីរ៉ាមីតនៅតែបន្តកសាងជាច្រើននៅតាមទីក្រុងសំខាន់ៗនៃអរិយធម៌គុស ប៉ុន្តែទំហំ និងកម្ពស់នៃសំណង់ប្រាសាទហាក់បីដូចជាមានទំហំតូច និងទាបជាងសំណង់ប្រាសាទពីរ៉ាមីតក្នុងអរិយធម៌អេហ្ស៊ីប។ តំបន់ភ្នំ Gebel Barkal ដែលជាទីតាំងនៃទីក្រុង ណាប៉ាតា (Napata) (១៤០០ឆ្នាំ ទៅ ១១០០ឆ្នាំមុនគ.ស.)។ នៅក្នុងទីក្រុង Napata មានសំណង់ប្រាសាទប្រមាណជាង ១៣ ដែល៣ទីតាំងត្រូវបានគេដឹង

---

[១] https://www.nationalgeographic.org/media/kingdoms-kush/

[២] https://www.history.com/news/7-influential-african-empires

អត្ថបទដោយ៖ អេង តុលា

ថា ជារាំង និងសំណង់ប្រាសាទពីរ៉ាមីតផ្សេងៗទៀត។[៣] នៅឆ្នាំ ២០០៣ តំបន់នៃភ្នំនេះត្រូវបានដាក់បញ្ចូលក្នុងសម្បត្តិបេតិកភណ្ឌពិភពលោក និងសំណង់ប្រាសាទខ្លះៗត្រូវបានជួសជុលដោយគម្រោងសំណង់ពិភពលោក។[៤] ទីក្រុងផ្សេងទៀតដែលមានឈ្មោះថា មេរ៉ូ ( Meroe) ដែលស្ថិតនៅចន្លោះទន្លេ នីល (Nile) និងទន្លេអបារ៉ា (Atbara) ហើយក៏ជាទីក្រុងដ៏សំខាន់នៃអរិយធម៌នេះ ដែលជាទីក្រុង ផ្នែកនយោបាយ សាសនា និងរដ្ឋបាលរវាងស.វ.ទី៨ ដល់ស.វ.ទី៤មុនគ.ស. ដោយអ្នកស្រាវជ្រាវបានរកឃើញនូវទីតាំងបញ្ចុះសពនៅក្នុងទីក្រុងនេះ។[៥] នៅទីនោះអ្នកស្រាវជ្រាវបានរកឃើញមានសំណង់ប្រាសាទពីរ៉ាមីតប្រមាណជាង ២០០។[៦] រាល់សំណង់ស្ថាបត្យកម្មទាំងនោះ វាបានបង្ហាញឱ្យយើងឃើញអំពីការរីកចម្រើនផ្នែកវប្បធម៌ និងគំនិតនៃមនុស្សក្នុងអាណាចក្រគុស ដែលទាក់ទងនឹងចំណេះដឹងខ្ពស់ផ្នែកគណិតវិទ្យាក្នុងការគណនា ទម្ងន់ ប្លង់ និងលំហ ដើម្បីកសាងប្រាសាទពីរ៉ាមីត និងបច្ចេកទេសក្នុងការសំណង់សាសនាផ្សេងៗ។ វត្ថុសិល្បៈផ្សេងៗដែលត្រូវបានរកឃើញរួមមាន បដិមា កុលាភាជន៍ វត្ថុលោហៈធាតុ ក្នុងអរិយធម៌ គឺទទួលឥទ្ធិពលស្ទើរតែទាំងស្រុងពីអរិយធម៌អេហ្ស៊ីប ដែលស្ថិតនៅព្រំដែនក្បែរខាងរវាងអរិយធម៌ទាំងពីរនេះ (រូបលេខ៣-៦)។

ភាពរីកចម្រើននៃអាណាចក្រគុសក៏ត្រូវបានដួលរលំនៅស.វ.ទី៤មុនគ.ស. ដោយការឈ្លានពានទឹកដីពីសំណាក់អាណាចក្រ Aksum ដែលមានឥទ្ធិពលខ្លាំងក្លាជាងអរិយធម៌គុស។

តាមរយៈការបង្ហាញពត៌មានខាងលើនេះ បានបង្ហាញថា អរិយធម៌គុស ប្រៀបបាន ដូចនឹងអរិយធម៌អេហ្ស៊ីបទីពីរ និងមានឥទ្ធិពលខ្លាំងក្លាលើផ្នែកពាណិជ្ជកម្មជាមួយនឹងឧបទ្វីបដ៏ទៃទៀត ដូចជាការជួញដូរ ឧស្សាហកម្មដែក និងរ៉ែមាសជាដើម៕

---

[៣] https://www.wmf.org/project/gebel-barkal

[៤] Gebel Barkal and the Sites of the Napatan Region - UNESCO World Heritage Centre

[៥] https://whc.unesco.org/en/list/1336

[៦] 7 Influential African Empires - HISTORY

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីអេហ្ស៊ីបបុរាណ

ប្រភព៖ Khan academy

អត្ថបទដោយ៖ អេង តុលា





រូបលេខ២-៣ ៖ ទីក្រុង Napata និង Meroë

ប្រភព៖ Internet







រូបលេខ៤-៦៖ រូបបដិមា ធ្វើពីលោហ:ធាតុ
ក្នុងអរិយធម៌គុស
ប្រភព៖ https://www.metmuseum.org

## ឯកសារយោង

https://www.nationalgeographic.org/media/kingdoms-kush/

https://www.history.com/news/7-influential-african-empires

https://www.wmf.org/project/gebel-barkal
Gebel Barkal and the Sites of the Napatan Region - UNESCO World Heritage Centre

https://whc.unesco.org/en/list/1336

7 Influential African Empires - HISTORY

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា